អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន
## សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ នេះ សហព្រះរាជអាជ្ញាអន្តរជាតិ លោក អាន់ឌ្រូ ឃេលី បានដាក់ឡើងវិញនូវ សំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី និងសំណើសុំពន្យារពេលវេលាកំណត់ សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ០០៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ។

ការដាក់សំណើឡើងវិញទាំងនេះ គឺបន្ទាប់ពីមានសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញា កាលពីថ្ងៃទីសុក្រ ទី១០ ខែមិថុនា ឆ្នាំ២០១១ ដើម្បីធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នាចំនួនបួន អនុលោមតាម វិធាន ៧១(១) នៃ វិធានផ្ទៃក្នុងរបស់តុលាការ។ ការខ្វែងយោបល់គ្នាទាំងនេះត្រូវបានធ្វើឡើងជាការឆ្លើយតបទៅនឹងសេចក្តីសម្រេច របស់សហចៅក្រមស៊ើប អង្កេតដែលថា វិធានផ្ទៃក្នុង មិនទុកចន្លោះប្រហែងណាមួយឱ្យមានសកម្មភាពតែម្នាក់ ឯងទេ ហេតុដូច្នេះបានជាតម្រូវឱ្យមានការផ្ទេរអំណាចតាមវិធាន ១៣(៣) នៃវិធានផ្ទៃក្នុង ឬកំណត់ហេតុអំពី ការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១(១) ។

ទោះបីសហព្រះរាជអាជ្ញាអន្តរជាតិ បានអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់សហចៅក្រមស៊ើបអង្កេត និងបានដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយបល់គ្នានេះចំនួនបួន រួចហើយក៏ដោយ ក៏គាត់នៅតែប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ ដដែល ។ គាត់មិនទទួលយកនូវការបកស្រាយច្បាប់របស់សហចៅក្រមស៊ើបអង្កេត ដូច្នេះដោយអនុលោមតាមវិធាន ៧៤(២) និង ៧៥(១) សេចក្តីជូនដំណឹងមួយអំពីបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃសុក្រ ទី១០ ខែមិថុនា ឆ្នាំ២០១១ ។

ពាក់ព័ន្ធទៅនឹងការដាក់ជូនសារជាថ្មីឡើងវិញនូវសំណើទាំងបួន សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើដោយសេចក្តីគោរពថា សូមឱ្យលោកចៅក្រមប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយអនុលោមតាមវិធាន ៣៩.៤.ខ ហើយនិងសូមទទួលយកការដាក់ជូនសារជាថ្មីដែលហួសពេលកំណត់ទាំងនេះ ។ វិធាន៣៩.៤.ខ បានអនុញ្ញាតឱ្យសហ ចៅក្រមស៊ើបអង្កេត ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេល កំណត់ ។ ពីពេលមុនសហចៅក្រមស៊ើបអង្កេត ធ្លាប់បានពឹងផ្អែកលើវិធាន ៣៩.៤.ខ ដើម្បីពន្យារពេលកំណត់សម្រាប់ការដាក់ពាក្យរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងលេខ ០០៣[1] ។

សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចទៅតាមវិធាន ៥៥ និងច្បាប់ អវតក ដើម្បីធ្វើការដឹកនាំកិច្ចស៊ើបសួរ របស់ខ្លួនដែលប្រកបទៅដោយអនាគតិភាព និងដើម្បីចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត។ គោលការណ៍ជាសារវ័ន្តនានាដែលអង្គជំនុំជម្រះនេះពឹងផ្អែកទៅលើ ហើយគឺនៅលើគោលការណ៍ជាសារវ័ន្តនោះ ហើយដែលសហចៅក្រមស៊ើបអង្កេតធ្លាប់បានពឹងផ្អែករួចហើយដែរនោះ[2] គឺមាន វិធាន ២១ ។ វិធាននេះ និយាយអំពីភាពត្រឹមត្រូវភាពប្រាកដប្រជានៃច្បាប់ និងកិច្ចធានាការពារនូវផលប្រយោជន៍របស់ជនរងគ្រោះក៏ដូចជាគ្រប់ភាគីទាំងអស់នៅក្នុងកិច្ចដំណើរការនីតិវិធី ។ អង្គបុរេជំនុំជម្រះ ធ្លាប់បានសម្រេចថា នៅពេលដែលធ្វើការពិចារណាថាតើត្រូវអនុញ្ញាតឱ្យមានសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ឬមួយយ៉ាងណានោះ វាជា “កាតព្វកិច្ច”

---

[1] សេចក្តីប្រកាសព័ត៌មានរបស់ កសចស ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងសំណើនានាក្នុងសំណុំរឿងលេខ ០០៣ របស់ សហព្រះរាជអាជ្ញាអន្តរជាតិ កាលពីថ្ងៃទី៧ មិថុនា ២០១១ ។

[2] ឯកសារលេខ D20/3, ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣, ថ្ងៃទី៧ មិថុនា ២០១១, លេខ ERN 00702797-00702802, កថាខណ្ឌទី ១១ ។

ទាំងរបស់សហចៅក្រមស៊ើបអង្កេត និងទាំងរបស់អង្គបុរេជំនុំជម្រះ ដើម្បីធ្វើការពិចារណាលើ គោលការណ៍ជាសារវ័ន្តនានា ដែលបានចែងនៅក្នុងវិធាន ២១ របស់អង្គជំនុំជម្រះនេះ[3] ។

[3] ឯកសារលេខ D365/2/17, សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង, ២៧ កញ្ញា ២០១០, ERN 00597907-00597951, កថាខ័ណ្ឌទី៤៧ ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh